អត្ថបទសង្ខេប ខែ សីហា ឆ្នាំ ២០០២

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ
# ក្រសួងសុខាភិបាល

# ផែនការយុទ្ធសាស្ត្រសុខាភិបាល
# ឆ្នាំ ២០០៣-២០០៧





## បេសកកម្មរបស់ក្រសួងសុខាភិបាល

បេសកកម្មរបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺការសន្យាដើម្បីធានានូវសមធម៌ ក្នុងវិស័យបើកទូលាយ, ផ្តល់ការថែទាំសុខភាពប្រកបដោយគុណភាពដល់ប្រជារាស្ត្រកម្ពុជាទាំងអស់ ជាពិសេសសំរាប់ប្រជារាស្ត្រក្រីក្រ និងនៅតំបន់ដែលមានតំរូវការខ្ពស់ តាមរយៈទិសដៅធនធាន ។



## តំលៃរបស់ក្រសួងសុខាភិបាល

- សិទ្ធិចំពោះសុខភាព
- សមធម៌
- គាំពារដល់អ្នកក្រីក្រ

## គោលការណ៍របស់ក្រសួងសុខាភិបាល

- ការពារដល់ជនដែលងាយនឹងទទួលគ្រោះថ្នាក់
- ស្តាប់នូវសំណូមពររបស់ប្រជារាស្ត្រ
- លទ្ធភាពបង់ថ្លៃ និងនិរន្តរភាព
- ផ្តោតការយកចិត្តទុកដាក់ទៅលើតំបន់ជនបទ និងតំបន់ក្រីក្រក្នុងទីក្រុង
- កសាងសមត្ថភាព រួមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស
- ការគ្រប់គ្រងវិស័យបើកទូលាយ
- ផ្តល់សេវាសុខាភិបាលដែលមានគុណភាពខ្ពស់ ផ្អែកទៅលើការអនុវត្តន៍ជាក់ស្តែង
- អភិបាលកិច្ចល្អ និងការទទួលខុសត្រូវ



# គោលនយោបាយសុខាភិបាល ២០០៣_២០០៧

គោលនយោបាយសុខាភិបាល ធ្វើឡើងដោយផ្អែកទៅលើគោលនយោបាយសុខាភិបាលជាតិ ដែលមាននៅក្នុងសៀវភៅ "ការវិភាគស្ថានភាពសុខភាពនៅឆ្នាំ ១៩៩៨ និង ទិសដៅសំរាប់ការអភិវឌ្ឍន៍សុខាភិបាលឆ្នាំ ១៩៩៩-២០០៣" ។

សមាសធាតុ ១៣ ដូចតទៅនេះ ដែលបង្កើតបានជាគោលនយោបាយសុខាភិបាល ផ្តល់មូលដ្ឋានសំរាប់ផែនការយុទ្ធសាស្ត្រ ។ក្នុងនោះគោលនយោបាយនីមួយៗមានយុទ្ធសាស្ត្រមួយ ឬច្រើនដែលផ្តើមចេញពីគោលនយោបាយនេះ ។

- អនុវត្តការគ្រប់គ្រងវិស័យបើកទូលាយ តាមរយៈទស្សនៈវិស័យរួម និងភាពជាដៃគូប្រកបដោយប្រសិទ្ធភាពក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ។
- ផ្តល់សេវាសុខាភិបាលមូលដ្ឋានជូនប្រជារាស្ត្រកម្ពុជា ដោយមានការចូលរួមពេញលេញពីសំណាក់សហគមន៍
- ផ្តល់សេវាឯកទេសសារវ័ន្ត ទៅតាមតំលៃសមស្រប
- ធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៃមុខងារហិរញ្ញវត្ថុ ផែនការ និងរដ្ឋបាល នៅក្នុងវិស័យសុខាភិបាល
- ផ្តោតការយកចិត្តទុកដាក់ជាអាទិភាពទៅលើការបង្ការជំងឺ ការកំចាត់ជំងឺឆ្លង ជំងឺរ៉ាំរ៉ៃ ជំងឺមិនឆ្លងមួយចំនួន របួស សុខភាពមនុស្សចាស់ មនុស្សវ័យជំទង់ និងក្រុមដែលងាយរងគ្រោះ ដូចជាអ្នកក្រីក្រ និងយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងបញ្ហាសុខភាពសាធារណៈផ្សេងៗ ។
- ផ្តោតការយកចិត្តទុកដាក់ជាអាទិភាពទៅលើការផ្តល់ការថែទាំសុខភាពដែលមានគុណភាពល្អ សំរាប់មាតា និងកុមារ រួមទាំងការផ្តល់ការថែទាំសម្ភពសារវ័ន្ត និងជំងឺកុមារ
- លើកកំពស់យ៉ាងសកម្មនូវរបៀបរបបរស់នៅរបស់ប្រជារាស្ត្រប្រកបដោយផាសុខភាព និងឥរិយាបទស្វែងរកការថែទាំសុខភាពត្រឹមត្រូវ
- ផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាសុខាភិបាលដែលមានប្រសិទ្ធភាព និងមានគុណភាព ពីអ្នកផ្តល់សេវាសុខាភិបាលទាំងអស់
- ប្រើប្រាស់អោយបានសមស្របបំផុតនូវធនធានមនុស្ស តាមរយៈការធ្វើផែនការត្រឹមត្រូវ ការគ្រប់គ្រងរួមទាំងការបែងចែកបុគ្គលិក និងការលើកកំពស់សមត្ថភាពបុគ្គលិកនៅក្នុងប្រព័ន្ធសុខាភិបាល
- បង្កើនការលើកកំពស់ភាពជាដៃគូរវាងសេវាសាធារណៈ និងសេវាឯកជន ក្នុងវិស័យសុខាភិបាលប្រកបដោយប្រសិទ្ធភាពសំរាប់ការថែទាំសុខភាពមូលដ្ឋាន និងការថែទាំឯកទេស
- ប្រើប្រាស់ពត៌មានសុខាភិបាលប្រកបដោយប្រសិទ្ធភាព សំរាប់ការធ្វើផែនការដែលផ្អែកលើការអនុវត្តន៍ជាក់ស្តែង ការងារគ្រប់គ្រង ការត្រួតពិនិត្យតាមដាន និងការវាយតំលៃនៅក្នុងវិស័យសុខាភិបាល
- អនុវត្តន៍ប្រព័ន្ធហិរញ្ញប្បទានសុខាភិបាល ដើម្បីលើកកំពស់លទ្ធភាពស្មើភាពក្នុងការប្រើប្រាស់សេវាអាទិភាព ជាពិសេសសំរាប់អ្នកក្រីក្រ
- ពង្រឹងការអនុវត្តន៍ និងអភិវឌ្ឍន៍ថែមទៀតនូវច្បាប់សុខាភិបាលសមស្រប ដើម្បីការពារសុខភាពរបស់អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវា

គោលនយោបាយសុខាភិបាល

# ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៣-២០០៧
# សង្ខេប

ឯកសារនេះ គឺជាការសង្ខេបនៃផែនការយុទ្ធសាស្ត្រសំរាប់វិស័យសុខាភិបាល ក្នុងប្រទេសកម្ពុជា ។

ទស្សនៈវិស័យនៃផែនការយុទ្ធសាស្ត្រ គឺដើម្បីធ្វើអោយសុខភាពរបស់ប្រជារាស្ត្រកម្ពុជា មានភាពល្អប្រសើរឡើង និងមានការខុសប្លែកពីមុន ។

គោលបំណងនៃផែនការយុទ្ធសាស្ត្រ គឺដើម្បីផ្តល់ទិសដៅអភិវឌ្ឍន៏វិស័យសុខាភិបាលសំរាប់រយៈពេល៥ឆ្នាំទៅមុខ ។ ជារួមទិសដៅរាជរដ្ឋាភិបាល គឺផ្តោតការយកចិត្តទុកដាក់ ទៅលើសកម្មភាពរបស់ក្រសួងសុខាភិបាល និងគ្រប់អ្នកដែលពាក់ព័ន្ធទាំងអស់ ដើម្បីឈានទៅដល់លទ្ធផលរួមមួយដែលបានគ្រោងទុកក្នុងផែនការរបស់រាជរដ្ឋាភិបាល ។

ដើម្បីធ្វើអោយសុខភាពប្រជារាស្ត្រកម្ពុជា មានការរីកចំរើនដោយមានសុខមាលភាព ក្រសួងសុខាភិបាល បានរៀបចំជាលើកដំបូងនូវផែនការយុទ្ធសាស្ត្ររួម ដូចខាងក្រោម :

- ផ្នែកឯកជន និងដៃគូសុខាភិបាល ក៏ដូចជាបុគ្គលិកសុខាភិបាល និងផ្នែកពាក់ព័ន្ធដទៃទៀត ធ្វើការរួមគ្នាក្នុងការផ្តល់សេវាថែទាំសុខភាពនៅក្នុងការគ្រប់គ្រងវិស័យបើកទូលាយ ។
- រៀបចំអោយមាននូវបេសកកម្ម តំលៃ គោលការណ៏ និងគោលនយោបាយរបស់ក្រសួងសុខាភិបាល ។
- ក្នុងចំណោមយុទ្ធសាស្ត្រចំនួន ២០ នៃផ្នែកការងារជាអាទិភាពចំនួន ៦ និងយុទ្ធសាស្ត្រសំខាន់ៗចំនួន ៨ ដែលបានជ្រើសរើសក្នុងចំណោមយុទ្ធសាស្ត្រទាំង ២០នេះ ត្រូវបានកំណត់ឡើងតាមរយៈការពិភាក្សាពិគ្រោះយោបល់ ដ៏ទូលំទូលាយ ។
- លទ្ធផលសុខភាព ត្រូវបានបញ្ជាក់ច្បាស់លាស់សំរាប់វិស័យទាំងមូល ។ នេះមានន័យថា យើងត្រូវទទួលអោយបានជោគជ័យក្នុងការអនុវត្តន៏ការងារ បើសិនជាយើងចង់អោយមានការរីកចំរើន និងសុខមាលភាពផ្នែកសុខភាព របស់ប្រជារាស្ត្រ ។
- យើងនៅតែផ្តល់ការយកចិត្តទុកដាក់កាន់តែច្រើនថែមទៀត ទៅលើជំងឺរ៉ាំរ៉ៃ និងបញ្ហាសុខភាពសាធារណៈដែលកើតឡើងថ្មីៗផ្សេងទៀត ។ យើងត្រូវការការពារប្រជារាស្ត្រពីជំងឺផ្សេងៗ ដូចជា មហារីកដែលបណ្តាលមកពីការជក់បារី ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ និងនៅផ្ទះ ឬគ្រោះថ្នាក់ចរាចរ ដែលបណ្តាលអោយមានបញ្ហាសុខភាព ។
- ការអភិវឌ្ឍន៏ផែនការយុទ្ធសាស្ត្រ ដែលផ្សារភ្ជាប់ទៅនឹងវដ្តនៃការធ្វើផែនការសកម្មភាព-ផែនការថវិកា និងគំរោងចំណាយរយៈពេលមធ្យម ។ ក្នុងការធ្វើផែនការត្រូវគិតគូរទៅលើអ្វីដែលធ្វើអោយមានការប្រែប្រួលខុសពីមុន និងធ្វើអោយប្រាកដថាថវិកាត្រូវចំណាយទៅលើអ្វីដែលជាអាទិភាព និងធ្វើអោយមានការរីកចំរើនខុសប្លែកពីមុន ។

## ស្ថានភាពសុខភាព និងប្រជាសាស្ត្របច្ចុប្បន្ន

ការវាយតំលៃនៃអាំងឌីកាទ័រសុខភាព និងប្រជាសាស្ត្រ ក្នុងប្រទេសកម្ពុជា

| | |
|---|---|
| អាយុកាលរំពឹងទុកពីកំណើត (១៩៩៨) | ៥៨,៣(ចំពោះស្ត្រី) ៥៤,៥ (ចំពោះបុរស) |
| អត្រាសាយកូន* | ៤,០ |
| អត្រាមរណភាពនៃមាតា* | ៤៣៧នាក់ក្នុងចំណោមកូនកើតរស់ ១០០.០០០នាក់ |
| អត្រាមរណភាពនៃទារក* | ៩៥នាក់ ក្នុងចំណោមកូនកើតរស់ ១.០០០នាក់ |
| អត្រាមរណភាពនៃកុមារអាយុក្រោម ៥ឆ្នាំ* | ១២៥នាក់ ក្នុងចំណោមកូនកើតរស់ ១.០០០នាក់ |
| ភាគរយនៃកុមារអាយុក្រោម ៥ឆ្នាំ ដែលក្រិន* | ៤៥% |
| ភាគរយនៃកុមារដែលមានទំងន់មិនគ្រប់* | ៤៥% |
| អត្រាអាំងស៊ីដង់នៃជំងឺរបេង (២០០១) | ៥៤០នាក់ ក្នុងចំណោមប្រជារាស្ត្រ ១០០,០០០នាក់ |
| អត្រាអាំងស៊ីដង់នៃជំងឺគ្រុនចាញ់ (២០០១) | ៨នាក់ ក្នុងចំណោមប្រជារាស្ត្រ ១.០០០នាក់ |
| អត្រាប្រេវ៉ាឡង់ហ៊ីវ/អេដស៍ក្នុងចំណោមប្រជារាស្ត្រអាយុពី១៥-៤៩ឆ្នាំ* | ២,៨% |

*(២០០០)

ការធ្វើអោយប្រសើរឡើងនូវអាំឌីកាទ័រទាំងនេះ ត្រូវបានបញ្ជាក់នៅក្នុងលំដាប់ការងារ សំរាប់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ ។ ការលើកកំពស់សុខភាព នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គម ។ បច្ចុប្បន្ន ប្រហែល ៣៦% នៃប្រជារាស្ត្ររស់នៅក្រោមបន្ទាត់ក្រីក្រ និងប្រហែល ៣២%នៃស្ត្រីមិនចេះអក្សរ ។

## អាទិភាពនៃបញ្ហាសុខភាព និងប្រជាសាស្ត្រខាងក្រោម ដែលត្រូវដោះស្រាយ

- កំរិតខ្ពស់នៃអត្រាស្លាប់របស់ទារក និងកុមារ រួមមានការស្លាប់ក្រោយពេលសំរាលកូន ការកើតជំងឺ និងស្លាប់ដោយសារជំងឺរាគ ជំងឺរលាកផ្លូវដង្ហើមស្រួច ជំងឺដែលអាចការពារបានដោយវ៉ាក់សាំង គ្រុនចាញ់ និងគ្រុនឈាម
- កំរិតខ្ពស់នៃអត្រាកង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រី និងកុមារ
- កំរិតខ្ពស់នៃអត្រាស្លាប់នៃមាតា និងការស្លាប់ដោយភាពគ្រាំគ្រាដែលបណ្តាលមកពីការមានផ្ទៃពោះ ឬការសំរាលកូន និងការរំលូតកូនដែលមានការឆ្លងរោគ
- កំរិតខ្ពស់នៃអត្រាស្លាប់ដែលបណ្តាលមកពីជំងឺឆ្លង ដូចជា អេដស៍ របេង និងគ្រុនចាញ់
- អត្រាសាយកូនសរុបខ្ពស់
- ការកើនឡើងនៃចំនួនប្រជាជន
- ការប្រព្រឹត្តប្រកបដោយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើប្រាស់ និងអ្នកផ្តល់សេវា រួមមាន ការរាលដាលនៃរបៀបរបបរស់នៅដែលមិនមានសុខភាព និងឥរិយាបទមិនត្រឹមត្រូវក្នុងការស្វែងរកការថែទាំសុខភាព

ប្រជារាស្ត្រដែលមានអាយុ ៦៥ឆ្នាំ ឬលើសពីនេះ នឹងមានចំនួនកើនឡើង ទន្ទឹមនឹងនេះដែរ ក៏មានការកើនឡើងនូវជំងឺមិនឆ្លង ជំងឺរ៉ាំរ៉ៃជាច្រើន ដូចជា ជំងឺបេះដូង-សរសៃឈាម, ជំងឺមហារីក និងជំងឺទឹកនោមផ្អែម ។ ដូចគ្នានេះដែរ នៅក្នុងពេលដែលវិស័យពាណិជ្ជកម្ម និងឧស្សាហកម្មកំពុងរីកដុះដាល វិស័យសុខាភិបាលនឹងជួបប្រទះនូវការកើនឡើងនូវចំនួនរបួស និងគ្រោះថ្នាក់ដែលទាក់ទងទៅនឹងការងារ និងគ្រោះថ្នាក់ចរាចរប្រសិនបើគ្មានការយកចិត្តទុកដាក់បង្ការទេនោះ ។ បញ្ហាមួយទៀត គឺការចំណាយរបស់គ្រួសារជាមធ្យមលើសុខភាពប្រហែល ២៨ដុល្លាអាមេរិកក្នុងប្រជារាស្ត្រ ១នាក់ ។ ៨០% ក្នុងចំណោមប្រជារាស្ត្រដែលទទួលការថែទាំសុខភាព ត្រូវប្រើប្រាស់ប្រាក់សន្សំសំរាប់ចិញ្ចឹមជីវិត ឬប្រាក់កម្ចី ឬប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិ ដើម្បីចំណាយលើការថែទាំសុខភាព ។បញ្ហាដែលរៀបរាប់ខាងលើ នឹងមានផលប៉ះពាល់ទៅលើគ្រួសារស្ទើរតែទាំងអស់ នៅក្នុងប្រទេសយើង ។ ក្រសួងសុខាភិបាលកំពុងធ្វើការដោះស្រាយជាបណ្តើរៗចំពោះបញ្ហាទាំងនេះ ហើយកំពុងទទួលបាននូវសញ្ញាជោគជ័យ គួរអោយកត់សំគាល់ ។

## គោលដៅរួមនៃផែនការយុទ្ធសាស្ត្រ គឺ :

បង្កើនការអភិវឌ្ឍន៍វិស័យសុខាភិបាល ដើម្បីលើកកំពស់សុខភាពប្រជារាស្ត្រកម្ពុជា ជាពិសេស មាតា និងកុមារ ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ។

## លទ្ធផលដែលសំរេចបានពី គោលដៅខាងលើនេះ រួមមាន :

- ការថយចុះអត្រាស្លាប់នៃទារក
- ការថយចុះអត្រាស្លាប់នៃកុមារ
- ការថយចុះអត្រាស្លាប់នៃមាតា
- ធ្វើអោយប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភ ក្នុងចំណោមកុមារ និងស្ត្រី
- ការថយចុះអត្រាសាយកូន
- ការថយចុះការចំណាយក្នុងគ្រួសារលើសុខភាព ជាពិសេសក្នុងចំណោមអ្នកក្រីក្រ
- ប្រព័ន្ធសុខាភិបាលដែលមានប្រសិទ្ធភាព និងប្រសិទ្ធភាពចំណាយ

## ផ្នែកការងារអាទិភាពសំខាន់ៗ

ដើម្បីទទួលបាននូវលទ្ធផល រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពទៅនឹងផ្នែកការងារទាំង ៦ នៅក្នុងរយៈពេលនៃផែនការយុទ្ធសាស្ត្រ ២០០៣-២០០៧ :

- ការផ្តល់សេវាសុខាភិបាល
- ការផ្លាស់ប្តូរឥរិយាបទ
- លើកកំពស់គុណភាព
- ការអភិវឌ្ឍន៍ធនធានមនុស្ស
- ហិរញ្ញប្បទានសុខាភិបាល
- ការអភិវឌ្ឍន៍ស្ថាប័ន

## ជំនួយក្នុងការអនុវត្តន៍ការងារ

យើងបានរៀបចំជា ៤ វ៉ូលូម ក្នុងផែនការយុទ្ធសាស្ត្រនេះ ។ វ៉ូលូម ១ គឺជាឯកសារគោលសំខាន់នៃផែនការយុទ្ធសាស្ត្រ ។ ដើម្បីជួយដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ អោយទទួលបានជោគជ័យ ក្រសួងបានអភិវឌ្ឍបែបបទ សំរាប់ប្រតិបត្តិមួយចំនួនដែលមានរៀបរាប់ក្នុងទំព័របន្ទាប់ ។ ហើយក៏មានការពន្យល់ដែរនៅក្នុង វ៉ូលូម ២, ៣ និង ៤ ។ ឯកសារក្នុងវ៉ូលូម ២, ៣, ៤ នេះ គឺជាឯកសារដើម្បីជំនួយដល់ការអនុវត្តន៍ ។ វ៉ូលូមទី ២ រៀបរាប់អំពីការធ្វើផែនការ និងការចំណាយ, វ៉ូលូមទី ៣ ពន្យល់អំពីការពិនិត្យតាមដាន និងវាយតំលៃ និងវ៉ូលូម ៤ គឺអត្ថាធិប្បាយអំពី ផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលនឹងត្រូវរៀបចំជារៀងរាល់ឆ្នាំ ។ ក្រសួងសុខាភិបាលក៏កំពុងពិនិត្យកែសំរួលបែបបទធ្វើផែនការ និងពិនិត្យឡើងវិញ នូវវិវដ្តធ្វើផែនការសកម្មភាព-ផែនការថវិកាផងដែរ ។ គ្រប់វ៉ូលូមទាំងអស់មានជា ភាសាខ្មែរ និងភាសាអង់គ្លេស ។

# យុទ្ធសាស្ត្រ

## យុទ្ធសាស្ត្រ

នៅក្នុងតារាងខាងក្រោមមានយុទ្ធសាស្ត្រចំនួន ២០ ដែលមានក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាល ។ យុទ្ធសាស្ត្រទាំងអស់ គឺជាយុទ្ធសាស្ត្រសំខាន់ ប៉ុន្តែមានយុទ្ធសាស្ត្រអាទិភាពចំនួន ៨ ក្នុងចំណោមយុទ្ធសាស្ត្រទាំងនេះជាយុទ្ធសាស្ត្រអាទិភាពសំខាន់បំផុត ។ មានយុទ្ធសាស្ត្រ៣ដំបូងមកពីផ្នែកផ្តល់សេវាសុខាភិបាល និងយុទ្ធសាស្ត្រ ១ ដំបូងមកពីផ្នែកការងារនិមួយៗផ្សេងទៀត ។

## ការផ្តល់សេវាសុខាភិបាល

- បន្តលើកកំពស់ការគ្របដណ្តប់សេវា និងលើកកំពស់លទ្ធភាពប្រើប្រាស់សេវាសុខាភិបាល ជាពិសេសសំរាប់អ្នកក្រីក្រ និងក្រុមងាយទទួលរងគ្រោះដទៃទៀតតាមរយៈការធ្វើផែនការទីតាំងមូលដ្ឋានសុខាភិបាល ។
- ពង្រឹងការផ្តល់សេវាសុខាភិបាលជាមូលដ្ឋាន ដែលមានគុណភាព តាមរយៈមណ្ឌលសុខភាព ក្នុងការផ្តល់សេវាសំណុំ សកម្មភាពអប្បរមា ។
- ពង្រឹងការផ្តល់ការថែទាំដែលមានគុណភាព ពិសេសសំរាប់សម្ភព និងជំងឺកុមារ នៅក្នុងមន្ទីរពេទ្យ តាមរយៈ វិធានការដូចជាសេវាសំណុំសកម្មភាពបង្គ្រប់ ។
- ពង្រឹងការគ្រប់គ្រងនូវការធ្វើអន្តរាគមន៍ដែលមានប្រសិទ្ធភាព ដើម្បីត្រួតពិនិត្យជំងឺឆ្លង ។
- ពង្រឹងការងារគ្រប់គ្រង និងគ្របដណ្តប់សេវាទ្រទ្រង់ ដូចជា មន្ទីរពិសោធន៍ សុវត្ថិភាពឈាម ការបញ្ជូនអ្នកជំងឺ ឱសថ បរិក្ខារនិងសំភារៈវេជ្ជសាស្ត្រ ការថែទាំ និងការដឹកជញ្ជូន ។

## ការផ្លាស់ប្តូរឥរិយាបទ

- ការផ្លាស់ប្តូរទៅរកឥរិយាបទល្អរបស់អ្នកផ្តល់សេវាសុខាភិបាលក្នុងវិស័យបើកទូលាយ ដើម្បីបង្កើន ការឆ្លើយតបទៅនឹងតំរូវការរបស់អ្នកប្រើប្រាស់សេវា ជាពិសេសអ្នកក្រីក្រ តាមរយៈការលើកកំពស់ការភ្ញាក់រលឹក និង ការកសាងជំនាញលើការប្រាស្រ័យទាក់ទង ។
- ផ្តល់សិទ្ធិអំណាចដល់អ្នកប្រើប្រាស់សេវា ជាពិសេសស្ត្រី ដើម្បីអោយគេអាចប្រាស្រ័យទាក់ទងជិតស្និទ្ធជាមួយ អ្នកដែលពាក់ព័ន្ធដទៃទៀតក្នុងការអភិវឌ្ឍន៍សេវាសុខាភិបាលដែលមានគុណភាព តាមរយៈប្រព័ន្ធឃោសនា និង ការប្រាស្រ័យទាក់ទងជាមួយសាធារណៈជន ។
- លើកកំពស់របៀបរបបរស់នៅប្រកបដោយសុខមាលភាព និងអាកប្បកិរិយាត្រឹមត្រូវក្នុងការស្វែងរកការថែទាំសុខភាពតាមរយៈការគាំទ្រសុខភាពបរិស្ថាន ការអនុវត្តន៍ ការផ្តល់ប្រឹក្សា និងសកម្មភាពផ្លាស់ប្តូរឥរិយាបទ ។

## ការលើកកំពស់គុណភាពសេវា

- អភិវឌ្ឍន៍នូវវប្បធម៌គុណភាពក្នុងការផ្តល់សេវាសុខាភិបាលសាធារណៈ និងការគ្រប់គ្រងតាមរយៈការប្រើប្រាស់បទដ្ឋានគុណភាពរបស់ក្រសួងសុខាភិបាល ។
- អភិវឌ្ឍន៍ និងអនុវត្តន៍នូវបទដ្ឋានអប្បបរមា និងសមស្របបំផុត (minimum and optimum standards) សំរាប់ផ្នែកសាធារណៈ និងឯកជន ដោយរួមបញ្ចូលនូវបញ្ហាគាំពារអ្នកក្រីក្រ និងបញ្ហាភេទ តាមរយៈការប្រើប្រាស់យន្តការត្រឹមត្រូវ ។



ការផ្តល់សេវាសុខាភិបាល



ការផ្លាស់ប្តូរឥរិយាបទ



ការលើកកំពស់គុណភាពសេវា

## ការអភិវឌ្ឍន៍ធនធានមនុស្ស

- ចូលរួមចំណែកលើកកំពស់សុខភាពប្រជារាស្ត្រ ជាពិសេសសុខភាពមាតានិងកុមារ តាមរយៈការបង្កើនចំនួនឆ្មប និងតាមរយៈការបង្កើនសមត្ថភាព និងជំនាញរបស់ឆ្មប ។
- ពង្រឹងការធ្វើផែនការធនធានមនុស្ស ដើម្បីកាត់បន្ថយការបែងចែកមិនត្រឹមត្រូវនូវចំនួន និងប្រភេទបុគ្គលិក តាមរយៈការកំណត់មុខតំណែងការងារ និងការបែងចែកបុគ្គលិកឡើងវិញ ។
- លើកកំពស់ជំនាញគ្រប់គ្រង និងជំនាញបច្ចេកទេស និងការបង្កើនសមត្ថភាពនៃបុគ្គលិកក្រសួងសុខាភិបាល ទាំងអស់តាមរយៈការបណ្តុះបណ្តាល និងការអប់រំគ្រប់ជ្រុងជ្រោយ និងមានគុណភាព និងវិធានការគាំទ្រ ។

## ហិរញ្ញប្បទានសុខាភិបាល

- ធានានូវការផ្តល់មូលនិធិគ្រប់គ្រាន់ និងទៀងទាត់ សំរាប់វិស័យសុខាភិបាល ជាពិសេសសំរាប់ការផ្តល់សេវា តាមរយៈការជំរុញអោយមានការបង្កើននូវធនធាន និងការពង្រឹងការងារគ្រប់គ្រងហិរញ្ញវត្ថុ ។
- បែងចែកធនធានហិរញ្ញវត្ថុ ដើម្បីលើកកំពស់លទ្ធភាពប្រើប្រាស់សេវាសុខាភិបាលជូនអ្នកក្រីក្រ តាមរយៈគំរោងហិរញ្ញប្បទានសុខាភិបាលផ្សេងៗ ។
- ធានានូវការចំណាយដែលមានប្រសិទ្ធភាព និងមានតម្លាភាព តាមរយៈការពង្រឹងការបែងចែកធនធាន និង ការត្រួតពិនិត្យតាមដាន ។

## ការអភិវឌ្ឍន៍ស្ថាប័ន

- កំណែទំរង់រចនាសម្ព័ន្ធ និងកំណែទំរង់ការងារគ្រប់គ្រង ប្រព័ន្ធ និងរបៀបរបបធ្វើការងាររបស់ក្រសួងសុខាភិបាល ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការផ្លាស់ប្តូរនៅក្នុងវិស័យសុខាភិបាល ។
- ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងផ្នែកសាធារណៈ និងផ្នែកឯកជន ដើម្បីលើកកំពស់លទ្ធភាពប្រើប្រាស់សេវាអោយមានគុណភាព និងតំលៃសមរម្យតាមរយៈការលើកកំពស់ការចូលរួមរបស់ផ្នែកឯកជន និងការពង្រឹង ការអនុវត្តន៍បទបញ្ជា ។
- បង្កើនសមត្ថភាពក្រសួងសុខាភិបាល ដើម្បីដោះស្រាយជំងឺរាំរ៉ៃ និងជំងឺមិនឆ្លងដទៃទៀត និងបញ្ហាសុខភាពដែលកើតឡើងថ្មីៗ តាមរយៈការលើកកំពស់ការយល់ដឹង និងការធ្វើផែនការគ្រប់ជ្រុងជ្រោយ ។
- បន្តអភិវឌ្ឍន៍វិស័យសុខាភិបាល ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសេវាសុខាភិបាល តាមរយៈ

  ក- លើកកំពស់ការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំនៅក្នុងវិស័យបើកទូលាយ
  ខ- បង្កើនការធ្វើវិមជ្ឈការ និងវិសហមជ្ឈការដែលមានប្រសិទ្ធភាព
  គ- ការដាក់អោយអនុវត្តន៍ជាផ្លូវការនូវការគ្រប់គ្រងក្នុងវិស័យបើកទូលាយ


ការអភិវឌ្ឍន៍ធនធានមនុស្ស


ហិរញ្ញប្បទានសុខាភិបាល


ការអភិវឌ្ឍន៍ស្ថាប័ន

# សកម្មភាពយុទ្ធសាស្ត្រ

ក្រសួងសុខាភិបាល មានភាពបទបែនក្នុងការឧបត្ថម្ភទៅនឹងតំរូវការផ្សេងៗ ។ ម៉្យាងទៀត ក្នុងផែនការយុទ្ធសាស្ត្រ មានតែ សកម្មភាពយុទ្ធសាស្ត្រប៉ុណ្ណោះ សំរាប់ការអនុវត្តន៏នៃយុទ្ធសាស្ត្រ (វ៉ូលូម ១, ឧបសម្ព័ន្ធ ខ) ។ នៅតាមថ្នាក់និមួយៗ ក៏ដូចជាថ្នាក់ខេត្ត និង ថ្នាក់ស្រុកនិមួយៗ នៃប្រព័ន្ធសុខាភិបាលនឹងរៀបចំសកម្មភាពលំអិត អាស្រ័យលើកត្តាផ្សេងៗដូចជា តួនាទី តំរូវការ និងបញ្ហាផ្សេងៗ ។ សកម្មភាពបែបនេះ នឹងឆ្លុះបញ្ចាំងក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ (វ៉ូលូម ៤ នៃផែនការយុទ្ធសាស្ត្រ) ។ សកម្មភាពទាំងនោះក៏មានទំនាក់ទំនងទៅនឹងទិសដៅ និង វិសាលភាព នៃផែនការយុទ្ធសាស្ត្រ វ៉ូលូម១ គំរោងចំណាយរយៈពេលមធ្យម វ៉ូលូម ២ និងគំរោងពិនិត្យតាមដាន និងវាយតំលៃ វ៉ូលូម ៣ ដែរ ។

## ឧទាហរណ៍ខាងក្រោម គឺជាសកម្មភាពយុទ្ធសាស្ត្រមួយចំនួន សំរាប់យុទ្ធសាស្ត្រសំខាន់ ៨ :

- *បន្តលើកកំពស់ការគ្របដណ្តប់សេវា និងលើកកំពស់លទ្ធភាពប្រើប្រាស់សេវាសុខាភិបាលជាពិសេសសំរាប់អ្នកក្រីក្រ និង ក្រុមងាយទទួលរងគ្រោះដទៃទៀត តាមរយៈការធ្វើផែនការទីតាំងមូលដ្ឋានសុខាភិបាល ។*

  បង្រួប់ផែនការគ្របដណ្តប់សុខាភិបាល

- *ពង្រឹងការផ្តល់សេវាសុខាភិបាលជាមូលដ្ឋានដែលមានគុណភាពតាមរយៈមណ្ឌលសុខភាពក្នុងការផ្តល់សេវាសំណុំសកម្មភាពអប្បរមា*

  ពិនិត្យឡើងវិញ និងកែសំរួលសំណុំសកម្មភាពអប្បរមា ដើម្បីឆ្លើយតបជាពិសេសទៅនឹងគោលដៅចំណុចនៃ ជំងឺអាទិភាពចំបងៗ និងបញ្ហាសុខភាពដទៃទៀតដូចជាជំងឺកង្វះអាហារូបត្ថម្ភ

- *ពង្រឹងការផ្តល់ការថែទាំដែលមានគុណភាព ពិសេសសំរាប់សម្ភព និងជំងឺកុមារ នៅក្នុងមន្ទីរពេទ្យតាមរយៈវិធានការដូចជាសេវាសំណុំសកម្មភាពបង្គ្រប់ ។*

  បញ្ចប់ និងអនុវត្តន៏សំណុំសកម្មភាពបង្គ្រប់ទៅតាមមុខងាររបស់មន្ទីរពេទ្យនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិដោយផ្អែកទៅតាមការអនុវត្តន៏ជាក់ស្តែង

- *ការផ្លាស់ប្តូរទៅរកឥរិយាបទល្អរបស់អ្នកផ្តល់សេវាសុខាភិបាល ក្នុងវិស័យបើកទូលាយ ដើម្បីបង្កើនការឆ្លើយតបទៅនឹងតំរូវការរបស់អ្នកប្រើប្រាស់សេវា ជាពិសេសអ្នកក្រីក្រ តាមរយៈការលើកកំពស់ការភ្ញាក់រលឹក និងការកសាងជំនាញលើការប្រាស្រ័យទាក់ទង*

  បង្កើនការយល់ដឹងរបស់អ្នកផ្តល់សេវាសុខាភិបាលសាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល អំពី គុណភាពសេវាសុខាភិបាល និងក្រមសីលធម៌វិជ្ជាជីវៈ (ការទទួលខុសត្រូវ) រួមទាំងជំនាញលើការប្រាស្រ័យទាក់ទងអន្តរបុគ្គល ។

- *អភិវឌ្ឍន៏នូវវប្បធម៌គុណភាពក្នុងការផ្តល់សេវាសុខាភិបាលសាធារណៈនិងការគ្រប់គ្រង តាមរយៈការប្រើប្រាស់ បទដ្ឋានគុណភាពរបស់ក្រសួងសុខាភិបាល ។*

  បង្កើតការិយាល័យធានាគុណភាព ដើម្បីទ្រទ្រង់ លើកទឹកចិត្ត និងជួយដល់អ្នកគ្រប់គ្រង ដើម្បីអភិវឌ្ឍន៏គុណភាពសេវាសំរាប់អតិថិជន / អ្នកប្រើប្រាស់សេវា ។

- *ចូលរួមចំណែកលើកកំពស់សុខភាពប្រជារាស្ត្រ ជាពិសេសសុខភាពមាតា និងកុមារ តាមរយៈការបង្កើនចំនួនឆ្មបនិងតាមរយៈការបង្កើនសមត្ថភាពនិងជំនាញរបស់ឆ្មប ។*

  បន្តផ្តល់វគ្គសិក្សាផ្នែកសុខភាពមាតា និងកុមារ រយៈពេល ៤ខែ ដល់បុគ្គលិកសុខាភិបាលមណ្ឌលសុខភាព ។

- *ធានានូវការផ្តល់មូលនិធិគ្រប់គ្រាន់និងទៀងទាត់ សំរាប់វិស័យសុខាភិបាលជាពិសេសសំរាប់ការផ្តល់សេវាតាមរយៈ ការជំរុញអោយមានការបង្កើននូវធនធាន និងការពង្រឹងការងារគ្រប់គ្រងហិរញ្ញវត្ថុ ។*

  ពង្រឹងការងារថវិកា និងផែនការហិរញ្ញវត្ថុ

- *កំណែទំរង់រចនាសម្ព័ន្ធ និងកំណែទំរង់ការងារគ្រប់គ្រង ប្រព័ន្ធ និងរបៀបរបបធ្វើការងាររបស់ក្រសួងសុខាភិបាល ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការផ្លាស់ប្តូរនៅក្នុងវិស័យសុខាភិបាល ។*

  បញ្ជាក់ច្បាស់លាស់នូវតួនាទី និងមុខងារ, លំដាប់ថ្នាក់នៃការទទួលខុសត្រូវ និងការធ្វើសេចក្តីសំរេច, ការផ្ទេរសិទ្ធិអំណាចនៅគ្រប់ថ្នាក់ទាំងអស់នៃក្រសួងសុខាភិបាល រួមទាំងកម្មវិធីជាតិ មន្ទីរពេទ្យជាតិ និងអង្គភាពសុខភាពជាតិដទៃទៀត ។




## ក្រសួងសុខាភិបាល

ផ្ទះលេខ ១៥១-១៥៣ មហាវិថីកម្ពុជាក្រោម ភ្នំពេញ កម្ពុជា

ទូរស័ព្ទ / ទូរសា : ៨៥៥ - ២៣ ៤២៦ ៨៤១ , ៧២៥ ៨៣៣

អ៊ីមែល : moh_cabinet@bigpond.com.kh